# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ឯកសណ្ឋាន សញ្ញាសម្គាល់ និងទង់នគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/០៨៣ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៨ ស្ដីពីរូបភាពលំដាប់សក្តិរបស់កងកម្លាំងនគរបាលជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៧៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្សចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៨៥ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីតួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋានធនធានមនុស្ស និងនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានធនធានមនុស្សនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣០៣ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីឯកសណ្ឋាន សញ្ញាសម្គាល់ និងទង់នគរបាលជាតិកម្ពុជា សម្រាប់បំពេញការងារប្រចាំថ្ងៃ ប្រតិបត្តិការ បេសកកម្ម កិច្ចប្រជុំ សិក្ខាសាលា សន្និបាត ព្រះរាជពិធី បុណ្យជាតិ បុណ្យប្រពៃណីជាតិ ពិធីសមោសរនិងជប់លៀង ទទួលភ្ញៀវអន្តរជាតិ និងពិធីផ្លូវការផ្សេងៗ ដើម្បីលើកកម្ពស់សីលធម៌ តម្លៃ សេចក្តីថ្លៃថ្នូរ ជំនឿទុកចិត្ត ឧត្តមភាព កិត្តិយស និងប្រសិទ្ធភាពនៃការបំពេញការងាររបស់មន្ត្រីនគរបាលជាតិកម្ពុជា ក្នុងការរក្សាការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមជូនប្រជាពលរដ្ឋនិងប្រទេសជាតិ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីនគរបាលជាតិកម្ពុជា។

**មាត្រា៣.-**

សញ្ញាសម្គាល់នគរបាលជាតិកម្ពុជា សំដៅដល់រូបព្រះសង្ហារ បន្ទោងរូបរាជសីហ៍ ស្លាកសញ្ញាដាក់លើដៃអាវខាងស្តាំ ស្លាកសញ្ញាដាក់លើដៃអាវខាងឆ្វេង សញ្ញាពាក់លើចុងកអាវ សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ សញ្ញាសម្គាល់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា សញ្ញាសក្តិ ផ្លាកឬស្លាកឈ្មោះនិងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជា សម្រាប់ពាក់លើឯកសណ្ឋាននគរបាលជាតិកម្ពុជា។

## ជំពូកទី២
## ឯកសណ្ឋាននគរបាលជាតិកម្ពុជា

**មាត្រា៤.-**

ឯកសណ្ឋាននគរបាលជាតិកម្ពុជា ត្រូវបានកំណត់ទៅតាមឋានានុក្រមរបស់នគរបាលជាតិកម្ពុជារួមមាន នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នាយនគរបាលជាន់ខ្ពស់ នាយនគរបាល និងនាយនគរបាលរង។

## ផ្នែកទី១
## ឯកសណ្ឋាននាយនគរបាលថ្នាក់ឧត្តមសេនីយ៍

**មាត្រា៥.-**

ឯកសណ្ឋាននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ មានចំនួន៧(ប្រាំពីរ)ប្រភេទ ដូចខាងក្រោមៈ

១- ឯកសណ្ឋានធំលេខ១ កុដ

២- ឯកសណ្ឋានធំលេខ២ វ៉ារី

៣- ឯកសណ្ឋានធំលេខ៣ ស្កិនស័រ

៤- ឯកសណ្ឋានលេខ៤ សាហារីយ៉ែន

៥- ឯកសណ្ឋានលេខ៥

៦- ឯកសណ្ឋានលេខ៦

៧- ឯកសណ្ឋានលេខ៧។

**មាត្រា៦.-**

ឯកសណ្ឋានធំលេខ១ កុដ សម្រាប់ប្រើក្នុងព្រះរាជពិធី បុណ្យជាតិ និងបុណ្យប្រពៃណីជាតិ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោមៈ

**ចំពោះបុរស**

ក- អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ ប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវ គ្មានឆែកខ្នង និងមានឡេវរូបព្រះសង្ហារពណ៌មាសចំនួន៧(ប្រាំពីរ)គ្រាប់ ដែលមានអង្កត់ផ្ចិត ២៤(ម្ភៃបួន)មិល្លីម៉ែត្រ។ អាវនេះមានហោប៉ៅខាងមុខចំនួន៤(បួន) គឺហោប៉ៅដេរប៉ះខាងលើមានចំនួន២(ពីរ) និងហោប៉ៅកាត់ខាងក្រោមមានចំនួន២(ពីរ)។ ហោប៉ៅដេរប៉ះខាងលើមានតួហោប៉ៅមូលចំកណ្ដាលជីបផ្នត់មួយ មានគម្របហោប៉ៅរាងចតុកោណកែង តែចុងគម្របទាំងសងខាងនិងកណ្ដាលរាងស្រួច និងមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិត ១៩(ដប់ប្រាំបួន)មិល្លីម៉ែត្រ។ ហោប៉ៅកាត់ខាងក្រោម មានគម្របហោប៉ៅរាងចតុកោណកែង ដែលមានជ្រុងខាងក្រោមទាំងសងខាងរាងមូល និងមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិត២១(ម្ភៃមួយ)មិល្លីម៉ែត្រ។ ក្បាច់ចុងកដៃអាវទាំងសងខាងឡើងមកលើប្រវែង ៨០(ប៉ែតសិប)មិល្លីម៉ែត្រ មានប៉ានក្រណាត់ប៉ាក់ក្បាច់ផ្កាដូងពណ៌មាសព័ទ្ធជុំវិញដៃអាវមានទទឹងប្រវែង១៥(ដប់ប្រាំ)មិល្លីម៉ែត្រ និងមានឡេវរូបព្រះសង្ហារពណ៌មាសចំនួន៣(បី)គ្រាប់ដាក់បញ្ឆោត ដែលមានអង្កត់ផ្ចិត១៩(ដប់ប្រាំបួន)មិល្លីម៉ែត្រ។

ខ- ខោជើងវែងពណ៌ខ្មៅ ដេរថ្នេរបង្កប់ ចង្កេះត និងគ្មានជីបក្លី ដែលមានហោប៉ៅចំនួន៣(បី) គឺហោប៉ៅកាត់ខាងក្រោយ១(មួយ) និងហោប៉ៅចំហៀងទាំងសងខាងចំនួន២(ពីរ)។ ហោប៉ៅកាត់ខាងក្រោយផ្នែកខាងស្ដាំ គ្មានគម្រប ចោះរន្ធដាក់ឡេវ១(មួយ)គ្រាប់ពណ៌ដូចខោ និងហោប៉ៅចំហៀងទាំងសងខាង ដេរបង្កប់តាមថ្នេរខោ។ ពីថ្នេរចង្កេះខោរហូតដល់ចុងជើងខោ មានប៉ានធ្នូតចំនួន២(ពីរ)ពណ៌បៃតង។ ប៉ានធ្នូតនីមួយៗ មានទទឹងប្រវែង១៥(ដប់ប្រាំ)មិល្លីម៉ែត្រ និងមានគម្លាតពីប៉ាននីមួយៗប្រវែង៥(ប្រាំ)មិល្លីម៉ែត្រ។

គ- មួកកាស្កេតធ្វើពីក្រណាត់ពណ៌ខ្មៅ។ ជើងមួកផ្នែកខាងមុខមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស ភ្ជាប់ដោយឡេវទាំងសងខាងរូបព្រះសង្ហារពណ៌មាសចំនួន២(ពីរ)គ្រាប់ ដែលមានអង្កត់ផ្ចិត ២០(ម្ភៃ)មិល្លីម៉ែត្រ។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាសពីចុងម្ខាងដល់ចុងម្ខាង។ នៅលើមុខមួកមានរូបព្រះសង្ហារពណ៌មាសប្រភេទ១។

ឃ- សក្តិប្រភេទ១។

ង- ខ្សែឥស្សរិយយសពណ៌មាស ធ្វើពីខ្សែសូតាសវេញចូលគ្នារាងសំប៉ែតទំហំ២០(ម្ភៃ)មិល្លីម៉ែត្រ ជាក្បាច់ផ្កាជូងចំនួន២(ពីរ)ខ្សែ គឺខ្សែខ្លីប្រវែង៤៧០(បួនរយចិតសិប)មិល្លីម៉ែត្រ ទៅ៥៧០ (ប្រាំរយចិតសិប)មិល្លីម៉ែត្រ និងខ្សែវែងប្រវែង៦០០(ប្រាំមួយរយ)មិល្លីម៉ែត្រ ទៅ៧០០ (ប្រាំពីររយ)មិល្លីម៉ែត្រ ព្រមទាំងមានខ្សែអមចំនួន២(ពីរ) ដែលមានម្ជុលពេជ្របន្តោកចំនួន២(ពីរ) ធ្វើពីលោហធាតុពណ៌មាសប្រវែង១០០(មួយរយ)មិល្លីម៉ែត្រ សម្រាប់ពាក់នៅលើស្មាខាងស្តាំ និងក្រវាត់ថ្ពក់នៅឡេវអាវទី៣ផ្នែកខាងក្នុងរាប់ពីលើ។

ច- ខ្សែក្រវាត់តូចធ្វើពីក្រណាត់នីឡុងពណ៌ខ្មៅ។ ក្បាលខ្សែក្រវាត់ធ្វើពីលោហធាតុពណ៌មាស ដែលមានបណ្តោយប្រវែង៥៥(ហាសិបប្រាំ)មិល្លីម៉ែត្រ និងទទឹងប្រវែង៣៧(សាមសិបប្រាំពីរ) មិល្លីម៉ែត្រ ព្រមទាំងមានរូបកម្រងកួរស្រូវទាំងសងខាង ដែលម្ខាងៗមានគ្រាប់ស្រូវចំនួន១៦ (ដប់ប្រាំមួយ)គ្រាប់អមលម្អទ្រូវរូបរាជសីហ៍ពណ៌មាសរាងជាស្នែងក្របី និងកន្ទុយខ្សែក្រវាត់ស្រោបលោហធាតុពណ៌មាស។

ឆ- ស្បែកជើងឃ្លុបស្បែកលាតកខ្លីពណ៌ខ្មៅ ចងខ្សែ មានកែងនិងមានស្រោមជើងពណ៌ខ្មៅកវែង។

**ចំពោះនារី**

ក- អាវមានរូបភាពដូចអាវបុរស ប៉ុន្តែកាត់តាមរបៀបជាអាវនារី។

ខ- សំពត់ដឹមីស្វារ៉េពណ៌ខ្មៅ មានសម្រុងត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្នត់ និងខាងក្រោយមានឆែក ពីថ្នេរចង្កេះសំពត់រហូតដល់ចុងសំពត់មានប៉ានធ្នូតចំនួន២(ពីរ) ពណ៌បៃតង។ ប៉ានធ្នូតនីមួយៗ មានទទឹងប្រវែង១៥(ដប់ប្រាំ)មិល្លីម៉ែត្រ និងមានគម្លាតពីប៉ាននីមួយៗប្រវែង៥(ប្រាំ)មិល្លីម៉ែត្រ ឬខោជើងវែងពណ៌ខ្មៅដូចខោបុរស។

គ- មួកសំបុកធ្វើពីក្រណាត់ពណ៌ខ្មៅ។ ជើងមួកផ្នែកខាងមុខមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស ភ្ជាប់ដោយឡេវទាំងសងខាងមានរូបព្រះសង្ហារពណ៌មាសចំនួន២(ពីរ)គ្រាប់ ដែលមានអង្កត់ផ្ចិត២០ (ម្ភៃ)មិល្លីម៉ែត្រ។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាសពីចុងម្ខាងដល់ចុងម្ខាង។ នៅលើមុខមួកមានរូបព្រះសង្ហារពណ៌មាសប្រភេទ២។

ឃ- សក្តិ ខ្សែឥស្សរិយយស និងខ្សែក្រវាត់ ដូចសក្តិ ខ្សែឥស្សរិយយស និងខ្សែក្រវាត់បុរស។

ង- ស្បែកជើងឃ្លុបស្បែកលាតកខ្លីពណ៌ខ្មៅ ចងខ្សែ មានកែងនិងមានស្រោមជើងពណ៌ខ្មៅកខ្លីសម្រាប់ប្រើជាមួយសំពត់ និងស្រោមជើងពណ៌ខ្មៅកវែងសម្រាប់ប្រើជាមួយខោ។

**មាត្រា៧.-**

**ឯកសណ្ឋានធំលេខ២ វ៉ារី** សម្រាប់ប្រើក្នុងពិធីផ្លូវការ បុណ្យជាតិ ការទទួលភ្ញៀវអន្តរជាតិ ការបំពេញបេសកកម្មនៅក្រៅប្រទេស និងសម្រាប់សាមីខ្លួនដែលត្រូវបានបំពាក់គ្រឿងឥស្សរិយយស ឋានន្តរសក្តិ និងប្រកាសមុខតំណែង ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖



9

**ចំពោះបុរស**

ក- អាវ មានពីរដូចតទៅៈ

- អាវវ៉ារីពណ៌ខៀវចាស់ កបើក ដៃវែង កាត់រាងអាវធំ ប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវ ផែកខ្នង និងមានឡេវរូបព្រះសង្ហារពណ៌មាសចំនួន៤(បួន)គ្រាប់ ដែលមានអង្កត់ផ្ចិត២៤(ម្ភៃបួន)មិល្លីម៉ែត្រ។ អាវនេះមានហោប៉ៅខាងមុខចំនួន៤(បួន) គឺហោប៉ៅដេរប៉ះខាងលើមានចំនួន២(ពីរ)និងហោប៉ៅកាត់ខាងក្រោមមានចំនួន២(ពីរ)។ ហោប៉ៅដេរប៉ះខាងលើនៅចំកណ្ដាលមានជីបផ្នត់មួយ និងមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិត១៩(ដប់ប្រាំបួន)មិល្លីម៉ែត្រ។ ហោប៉ៅកាត់ខាងក្រោម មានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិត២១(ម្ភៃមួយ)មិល្លីម៉ែត្រ។ គម្របទាំង៤(បួន)រាងចតុកោណកែង តែចុងគម្របទាំងសងខាងនិងកណ្ដាលរាងស្រួច។ នៅចុងកដៃអាវទាំងសងខាងដែលម្ខាងៗមានឡេវរូបព្រះសង្ហារពណ៌មាសចំនួន៣(បី)គ្រាប់ ដាក់បញ្ឆោត ដែលមានអង្កត់ផ្ចិត១៩(ដប់ប្រាំបួន)មិល្លីម៉ែត្រ។
- អាវសឺមីកឱបដៃវែងពណ៌ផ្ទៃមេឃ ដែលមានហោប៉ៅមួយគ្មានគម្របកាត់ស្រុង ដាក់ក្នុងខោសម្រាប់ពាក់ខាងក្នុងអាវវ៉ារី។

ខ- ខោជើងវែងពណ៌ខៀវចាស់ ដេរថ្នេរបង្កប់ ចង្កេះត គ្មានជីបភ្លី ដែលមានហោប៉ៅចំនួន៣(បី) គឺហោប៉ៅកាត់ខាងក្រោយ១(មួយ)និងហោប៉ៅចំហៀងទាំងសងខាងចំនួន២(ពីរ)។ ហោប៉ៅកាត់ខាងក្រោយនៅផ្នែកខាងស្ដាំ គ្មានគម្រប ចោះរន្ធដាក់ឡេវ១(មួយ)គ្រាប់ពណ៌ដូចខោ។ ហោប៉ៅចំហៀង ដេរបង្កប់តាមថ្នេរខោ។

គ- មួកកាស្កេតដូចមួកឯកសណ្ឋានធំលេខ១ ប៉ុន្តែធ្វើពីក្រណាត់ពណ៌ខៀវចាស់។

ឃ- សក្តិប្រភេទ២។

ង- ក្រវ៉ាត់កពណ៌ខៀវចាស់សម្រាប់ពាក់នៅកអាវសឺមីកឱបដៃវែងពណ៌ផ្ទៃមេឃ ដាក់ក្នុងអាវវ៉ារី។

ច- ខ្សែឥស្សរិយយសពណ៌មាស ធ្វើពីខ្សែសូតាសវេញចូលគ្នារាងសំប៉ែតទំហំ២០(ម្ភៃ)មិល្លីម៉ែត្រ។ ខ្សែនេះរៀបចំជាក្បាច់ផ្កាដូងចំនួន២(ពីរ)ខ្សែ គឺខ្សែខ្លីប្រវែង៥២០(ប្រាំរយម្ភៃ)មិល្លីម៉ែត្រទៅ៦២០(ប្រាំមួយរយម្ភៃ)មិល្លីម៉ែត្រ និងខ្សែវែងប្រវែង៧០០(ប្រាំពីររយ)មិល្លីម៉ែត្រ ទៅ៨០០(ប្រាំបីរយ)មិល្លីម៉ែត្រ ព្រមទាំងមានខ្សែអមចំនួន៣(បី)មានម្ជុលពេជ្របន្តោកចំនួន២(ពីរ) ធ្វើពីលោហធាតុពណ៌មាសប្រវែង១០០(មួយរយ)មិល្លីម៉ែត្រ សម្រាប់ពាក់នៅលើស្មាខាងស្ដាំ និងក្រវ៉ាត់ថ្កក់នៅឡេវអាវទី១ផ្នែកខាងក្នុងរាប់ពីលើ។ ក្នុងករណីបំពេញបេសកកម្មនៅក្រៅប្រទេស មន្ត្រីនគរបាលជាតិកម្ពុជាមិនតម្រូវឱ្យពាក់ខ្សែឥស្សរិយយសនេះទេ។

ឆ- ខ្សែក្រវ៉ាត់ ស្បែកជើង និងស្រោមជើង ដូចខ្សែក្រវ៉ាត់ ស្បែកជើង និងស្រោមជើងឯកសណ្ឋានធំលេខ១។

**ចំពោះនារី**

ក- អាវមានរូបភាពដូចអាវបុរស ប៉ុន្តែកាត់តាមរបៀបជាអាវនារី។

ខ- សំពត់ជីមីស្វារ៉េពណ៌ខៀវចាស់ មានសម្រុងត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្នត់ និងខាងក្រោយមានផែក ឬខោជើងវែងពណ៌ខៀវចាស់ដូចខោបុរស។

គ- មួកសំបុកដូចមួកឯកសណ្ឋានធំលេខ១ ប៉ុន្តែធ្វើពីក្រណាត់ពណ៌ខៀវចាស់។

ឃ- សក្តិ ក្រវ៉ាត់ក ខ្សែឥស្សរិយយស អាវសឺមី និងខ្សែក្រវ៉ាត់ ដូចសក្តិ ក្រវ៉ាត់ក ខ្សែឥស្សរិយយស អាវសឺមី និងខ្សែក្រវ៉ាត់បុរស។

ង- ស្បែកជើងនិងស្រោមជើងដូចឯកសណ្ឋានធំលេខ១។



៥

**មាត្រា៨._**

ឯកសណ្ឋានធំលេខ៣ ស្ពិនស័រ សម្រាប់ប្រើក្នុងពិធីសមោសរនិងជប់លៀង ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ចំពោះបុរស**

ក- អាវ មានពីរដូចតទៅ៖

- អាវស្ពិនស័រពណ៌ស កបើក ដៃវែង កាត់រាងអាវធំ ប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវ គ្មានឆែកខ្នង ជើងអាវផ្នែកខាងក្រោយខើចត្រឹមចង្កេះ មានហោប៉ៅ១(មួយ)កាត់មាត់បញ្ឆិតខាងឆ្វេងផ្នែកខាងលើ។ នៅមុខអាវផ្នែកខាងក្រោមមានបន្ទះសំប៉ែតមួយពណ៌ដូចអាវ មានបណ្ដោយប្រវែង៨០(ប៉ែតសិប)មិល្លីម៉ែត្រនិងទទឹងប្រវែង៥០(ហាសិប)មិល្លីម៉ែត្រ ដាក់ឡេវបង្កប់១(មួយ)គ្រាប់ពណ៌ដូចអាវ។ នៅមុខអាវទាំងសងខាង ដែលម្ខាងៗមានឡេវរូបព្រះសង្ការពណ៌មាសចំនួន៣(បី)គ្រាប់ មានអង្កត់ផ្ចិត២៤(ម្ភៃបួន)មិល្លីម៉ែត្រ ដាក់បញ្ឈោតរៀងបញ្ឆិតមកផ្នែកខាងក្រោម។ នៅចុងដៃអាវទាំងសងខាង ដែលម្ខាងៗមានឡេវរូបព្រះសង្ការពណ៌មាសចំនួន៣(បី)គ្រាប់ មានអង្កត់ផ្ចិត១៩(ដប់ប្រាំបួន)មិល្លីម៉ែត្រ ដាក់បញ្ឈោត។
- អាវសឺមីកឌុបដៃវែងពណ៌ស កាត់ស្រុង គ្មានហោប៉ៅ និងមានដេរផ្នេរផ្នត់តូចៗនៅផ្ទៃមុខអាវទាំងសងខាង ដែលម្ខាងៗមានចំនួន១៦(ដប់ប្រាំមួយ)ផ្នត់ ដាក់ក្នុងខោសម្រាប់ពាក់ខាងក្នុងអាវស្ពិនស័រ។

ខ- ខោដូចខោឯកសណ្ឋានធំលេខ១។

គ- មួកកាស្កេតដូចមួកឯកសណ្ឋានធំលេខ១។

ឃ- សក្តិប្រភេទ១។

ង- ណឹពណ៌ខ្មៅ។

ច- ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង ដូចខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងឯកសណ្ឋានធំលេខ១។

**ចំពោះនារី**

ក- អាវមានរូបភាពដូចអាវបុរស ប៉ុន្តែកាត់តាមរបៀបជាអាវនារី។

ខ- សំពត់និងខោ ដូចសំពត់និងខោឯកសណ្ឋានធំលេខ១។

គ- មួកសំបុកដូចមួកឯកសណ្ឋានធំលេខ១។

ឃ- សក្តិ ណឹ និងខ្សែក្រវាត់ ដូចសក្តិ ណឹ និងខ្សែក្រវាត់បុរស។

ង- ស្បែកជើងនិងស្រោមជើងដូចឯកសណ្ឋានធំលេខ១។

**មាត្រា៩._**

ឯកសណ្ឋានលេខ៤ សាហារីយ៉ែន សម្រាប់ប្រើក្នុងពិធីផ្លូវការ សិក្ខាសាលា សន្និបាត ការទទួលភ្ញៀវជាតិ អន្តរជាតិ កិច្ចប្រជុំ និងការបំពេញការងារប្រចាំថ្ងៃ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ចំពោះបុរស**

ក- អាវ មានពីរដូចតទៅ៖

- អាវសាហារីយ៉ែនពណ៌កាគី កបើក ដៃខ្លី កាត់រាងអាវធំ ប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវ ឆែកខ្នងនិងមានឡេវរូបព្រះសង្ការពណ៌មាសចំនួន៥(ប្រាំ)គ្រាប់ ដែលមានអង្កត់ផ្ចិត



៥

២១(ម្ភៃមួយ)មិល្លីម៉ែត្រ។ អាវនេះមានហោប៉ៅខាងមុខចំនួន៤(បួន) គឺហោប៉ៅដេរប៉ះខាងលើមានចំនួន២(ពីរ)និងហោប៉ៅដេរប៉ះខាងក្រោមមានចំនួន២(ពីរ)។ ហោប៉ៅដេរប៉ះខាងលើនៅចំកណ្តាលមានបត់ផ្នត់មួយនិងមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិត ១៩(ដប់ប្រាំបួន)មិល្លីម៉ែត្រ។ ហោប៉ៅដេរប៉ះខាងក្រោម នៅចំកណ្តាលបត់ផ្នត់មួយមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិត២១(ម្ភៃមួយ)មិល្លីម៉ែត្រ។ គម្របហោប៉ៅទាំង៤(បួន)រាងចតុកោណកែង តែចុងគម្របទាំងសងខាងនិងកណ្តាលរាងស្រួច។

- អាវយឺតដៃខ្លីពណ៌ស កមូល ស្តើង សម្រាប់ពាក់ខាងក្នុងអាវសាហារីយ៉ែន។

ខ- ខោជើងវែងពណ៌កាគី ដេរថ្នេរបង្កប់ ចង្កេះត និងគ្មានជីបភ្លី ដែលមានហោប៉ៅចំនួន៤(បួន) គឺហោប៉ៅក្រោយមានចំនួន២(ពីរ) និងហោប៉ៅចំហៀងមានចំនួន២(ពីរ)។ ហោប៉ៅកាត់ខាងក្រោយគ្មានគម្រប ចោះរន្ធដាក់ឡេវ១(មួយ)គ្រាប់ពណ៌ដូចខោ និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរខោ។

គ- មួកកាស្កេតដូចមួកឯកសណ្ឋានធំលេខ២។

ឃ- សក្តិប្រភេទ២។

ង- ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង ដូចខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងឯកសណ្ឋានធំលេខ១។

**ចំពោះនារី**

ក- អាវមានរូបភាពដូចអាវបុរស ប៉ុន្តែកាត់តាមរបៀបជាអាវនារី។

ខ- សំពត់ជីមីស្វារ៉េពណ៌កាគី មានសម្រុងត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្នត់ និងខាងក្រោយមានឆែក ឬខោជើងវែងពណ៌កាគីដូចខោបុរស។

គ- មួកសំបុកដូចមួកឯកសណ្ឋានធំលេខ២។

ឃ- សក្តិ ខ្សែក្រវាត់ និងអាវយឺត ដូចសក្តិ ខ្សែក្រវាត់ និងអាវយឺតបុរស។

ង- ស្បែកជើងនិងស្រោមជើងដូចឯកសណ្ឋានធំលេខ១។

## មាត្រា១០.-

ឯកសណ្ឋានលេខ៥ សម្រាប់ប្រើក្នុងពេលបំពេញការងារប្រចាំថ្ងៃ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោមៈ

**ចំពោះបុរស**

ក- អាវ មានពីរដូចតទៅៈ

- អាវពណ៌កាគី កឱប ដៃខ្លី ប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវ កាត់ស្រុង ដែលជើងអាវទាំងសងខាងរាងវៀលដាក់ក្នុងខោនិងមានឡេវចំនួន៥(ប្រាំ)គ្រាប់និងឡេវកអាវ១(មួយ)គ្រាប់ពណ៌ដូចអាវ។ អាវនេះមានហោប៉ៅដេរប៉ះខាងមុខផ្នែកខាងលើចំនួន២(ពីរ) នៅចំកណ្តាលបត់ផ្នត់មួយ មានគម្របហោប៉ៅរាងស្លឹកពោធិ៍ចោះរន្ធដាក់ឡេវ១(មួយ)គ្រាប់ពណ៌ដូចអាវ។
- អាវយឺតដៃខ្លីពណ៌ស កមូល ស្តើង សម្រាប់ពាក់ខាងក្នុងឯកសណ្ឋានលេខ៥។

ខ- ខោដូចខោឯកសណ្ឋានលេខ៤។

គ- មួកកាស្កេតដូចមួកឯកសណ្ឋានធំលេខ២ ឬមួកហ៊្វិកកីពណ៌ខៀវចាស់ធ្វើពីក្រណាត់ ជើងមួកផ្នែកខាងមុខមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាសពីចុងម្ខាងដល់ចុងម្ខាង និងនៅលើមុខមួកមានប៉ាក់រូបព្រះសង្ហារពណ៌មាសប្រភេទ២។



៤៥

ឃ- សក្តិប្រភេទ២។

ង- ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង ដូចខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងឯកសណ្ឋានធំលេខ១។

**ចំពោះនារី**

ក- អាវមានរូបភាពដូចអាវបុរស ប៉ុន្តែកាត់តាមរបៀបជាអាវនារី។

ខ- សំពត់ជីមីស្វារ៉េពណ៌កាគី មានសម្រុងត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្នត់ និងខាងក្រោយមានឆែក ឬខោជើងវែងពណ៌កាគីដូចខោបុរស។

គ- មួកសំបុកដូចមួកឯកសណ្ឋានធំលេខ២ ឬមួកហ៊ូកកីពណ៌ខៀវចាស់ដូចមួកបុរស។

ឃ- សក្តិ ខ្សែក្រវាត់ និងអាវយឺត ដូចសក្តិ ខ្សែក្រវាត់ និងអាវយឺតបុរស។

ង- ស្បែកជើងនិងស្រោមជើងដូចឯកសណ្ឋានធំលេខ១។

**មាត្រា១១.-**

ឯកសណ្ឋានលេខ៦ សម្រាប់ប្រើក្នុងពេលបំពេញការងារប្រចាំថ្ងៃ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ចំពោះបុរស**

ក- អាវ មានពីរដូចតទៅ៖

- អាវពណ៌កាគី កឧប ដៃវែង ប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវ កាត់ស្រុងដែលចុងដៃអាវឧបចោះរន្ធដាក់ឡេវ១(មួយ)គ្រាប់ពណ៌ដូចអាវ។ ជើងអាវទាំងសងខាងរាងវៀលដាក់ក្នុងខោ មានឡេវចំនួន៥(ប្រាំ)គ្រាប់ និងឡេវកអាវ១(មួយ)គ្រាប់ពណ៌ដូចអាវ។ អាវនេះមានហោប៉ៅដេរប៉ះខាងមុខផ្នែកខាងលើចំនួន២(ពីរ)នៅចំកណ្តាលបត់ផ្នត់មួយមានគម្របហោប៉ៅរាងស្លឹកពោធិ៍ចោះរន្ធដាក់ឡេវ១(មួយ)គ្រាប់ពណ៌ដូចអាវ។
- អាវយឺតដៃខ្លីពណ៌ស កមូល ស្តើង សម្រាប់ពាក់ខាងក្នុងឯកសណ្ឋានលេខ៦។

ខ- ខោដូចខោឯកសណ្ឋានលេខ៤។

គ- មួកកាស្កេតដូចមួកឯកសណ្ឋានធំលេខ២ ឬមួកហ៊ូកកីដូចមួកឯកសណ្ឋានលេខ៥។

ឃ- សក្តិប្រភេទ២។

ង- ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង ដូចខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងឯកសណ្ឋានធំលេខ១។

**ចំពោះនារី**

ក- អាវមានរូបភាពដូចអាវបុរស ប៉ុន្តែកាត់តាមរបៀបជាអាវនារី។

ខ- សំពត់ជីមីស្វារ៉េពណ៌កាគី មានសម្រុងត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្នត់ និងខាងក្រោយមានឆែក ឬខោជើងវែងពណ៌កាគីដូចខោបុរស។

គ- មួកសំបុកដូចមួកឯកសណ្ឋានធំលេខ២ ឬមួកហ៊ូកកីពណ៌ខៀវចាស់ដូចមួកបុរស។

ឃ- សក្តិ ខ្សែក្រវាត់ និងអាវយឺត ដូចសក្តិ ខ្សែក្រវាត់ និងអាវយឺតបុរស។

ង- ស្បែកជើងនិងស្រោមជើងដូចឯកសណ្ឋានធំលេខ១។

**មាត្រា១២.-**

ឯកសណ្ឋានលេខ៧ សម្រាប់ប្រើក្នុងប្រតិបត្តិការ បេសកកម្ម និងការហ្វឹកហាត់ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៧នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ចំពោះបុរស**

ក- អាវ មានពីរដូចតទៅ៖

- អាវពណ៌បៃតងចាស់ កបើកថ្ពេរឧប ដៃវែងបំពង់មានប៊ូលបង្កប់ខាងក្នុង ប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចអាវ កាត់ស្រុង ដែលចុងដៃអាវមានប៉ូលដាក់ឡេវចំនួន២(ពីរ)គ្រាប់ និងមានប៉ូលទាំងសងខាងត្រង់ចង្កេះខាងក្រោយដាក់ឡេវចំនួន២(ពីរ)គ្រាប់ពណ៌ដូចអាវ។ ជើងអាវត្រង់និងទ្រូងអាវមានសន្ទះដាក់ឡេវបង្កប់ចំនួន៤(បួន)គ្រាប់ពណ៌ដូចអាវ។ អាវនេះមានហោប៉ៅស្បោងខាងមុខចំនួន៤(បួន) គឺហោប៉ៅខាងលើមានចំនួន២(ពីរ) និងហោប៉ៅខាងក្រោមមានចំនួន២(ពីរ)។ ហោប៉ៅនេះមានជីបមាត់ចាបនៅចំកណ្តាលតួហោប៉ៅរាងមូលមានគម្របបញ្ឆិត សន្ទះអណ្តាតចោះរន្ធដាក់ឡេវបង្កប់។ ហោប៉ៅអាវខាងលើដាក់ឡេវ១(មួយ)គ្រាប់ពណ៌ដូចអាវ និងហោប៉ៅអាវខាងក្រោមដាក់ឡេវចំនួន២(ពីរ)គ្រាប់ពណ៌ដូចអាវ។
- អាវយឺតដៃខ្លីពណ៌បៃតងចាស់ កមូល ស្តើងសម្រាប់ពាក់ខាងក្នុងឯកសណ្ឋានលេខ៧។

ខ- ខោជើងវែងពណ៌បៃតងចាស់ ចង្កេះលាត ជីបក្បាលជង្គង់នៅទាំងសងខាង។ ចង្កេះខោមានខ្សែរឹតដែលមានហោប៉ៅចំនួន៦(ប្រាំមួយ) គឺហោប៉ៅមាត់បញ្ឆិតចំហៀងទាំងសងខាងមានចំនួន២(ពីរ) ហោប៉ៅកាត់ខាងក្រោយមានចំនួន២(ពីរ)មានគម្របបញ្ឆិតសន្ទះអណ្តាតចោះរន្ធដាក់ឡេវបង្កប់១(មួយ)គ្រាប់ និងហោប៉ៅស្បោងជង្គង់មានចំនួន២(ពីរ)មានជីបផ្នត់ពីរ តួហោប៉ៅជ្រុងមានគម្របបញ្ឆិតមានសន្ទះអណ្តាតចោះរន្ធដាក់ឡេវបង្កប់ចំនួន២(ពីរ)គ្រាប់ពណ៌ដូចខោ។ នៅចុងជើងខោមានខ្សែចង។

គ- មួកប៉េរ៉េក្រណាត់ពណ៌ខ្មៅ មានរូបព្រះសង្ហារប្រភេទ៣ នៅចំហៀងខាងឆ្វេង។

ឃ- សក្តិប្រភេទ៣។

ង- ខ្សែក្រវាត់តូចពណ៌ខ្មៅដូចខ្សែក្រវាត់ឯកសណ្ឋានធំលេខ១។

ច- ខ្សែក្រវាត់ធំ(សាំងទៀរ៉ុង) ពណ៌បៃតងចាស់ ក្រវាត់ពីក្រៅអាវលើគម្របហោប៉ៅអាវខាងក្រោម។

ឆ- ស្បែកជើងឃ្លុបស្បែកកវែងពាក់កណ្តាលស្មងជើងពណ៌ខ្មៅ ចងខ្សែ និងមានស្រោមជើងពណ៌ខ្មៅប្រវែងពាក់កណ្តាលស្មងជើង ហើយជើងខោបញ្ចូលក្នុងកស្បែកជើង។

**ចំពោះនារី**

ក- អាវមានរូបភាពដូចអាវបុរស ប៉ុន្តែកាត់តាមរបៀបជាអាវនារី។

ខ- ខោជើងវែងពណ៌បៃតងចាស់ដូចខោបុរស។

គ- មួក សក្តិ ខ្សែក្រវាត់ ស្បែកជើង ស្រោមជើង និងអាវយឺត ដូចមួក សក្តិ ខ្សែក្រវាត់ ស្បែកជើង ស្រោមជើង និងអាវយឺតបុរស។

## ផ្នែកទី២
## ឯកសណ្ឋាននាយនគរបាលជាន់ខ្ពស់

**មាត្រា១៣ .-**

ឯកសណ្ឋាននាយនគរបាលជាន់ខ្ពស់មានចំនួន៧(ប្រាំពីរ)ប្រភេទ ដូចឯកសណ្ឋាននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ដែលបានកំណត់ក្នុងផ្នែកទី១នៃអនុក្រឹត្យនេះ។ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួន ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៨នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោមៈ

ក- ក្បាច់ចុងកដៃអាវទាំងសងខាងនៃឯកសណ្ឋានធំលេខ១ មានប៉ានក្រណាត់លាតពណ៌មាសទទឹងប្រវែង១៥(ដប់ប្រាំ)មិល្លីម៉ែត្រ។

ខ- មួកកាស្កេតនិងមួកសំបុក នៅលើជើងមុខមួកមានខ្សែសូតាសភ្លោះពណ៌មាសវេញបញ្ចូលគ្នាចំនួន៣(បី)ផ្លុង។ នៅលើគែមក្បាំងមួកមានក្បាច់ភ្ញីទេសពណ៌មាស ដែលមានគម្លាតពីជើងមួកទាំងសងខាងចម្ងាយប្រវែង៤០(សែសិប)មិល្លីម៉ែត្រ។

គ- មួកហ៊្សកកី នៅលើគែមក្បាំងមួកមានក្បាច់ភ្ញីទេសពណ៌មាស ដែលមានគម្លាតពីជើងមួកទាំងសងខាងចម្ងាយប្រវែង៤០(សែសិប)មិល្លីម៉ែត្រ។

ឃ- ខ្សែឥស្សរិយយសពណ៌មាស ធ្វើពីខ្សែនីឡុងសម្រាប់ពាក់លើឯកសណ្ឋានធំលេខ១ និងឯកសណ្ឋានធំលេខ២។

របៀបនៃការប្រើឯកសណ្ឋាននាយនគរបាលជាន់ខ្ពស់ ដូចគ្នានឹងការប្រើឯកសណ្ឋាននាយនគរបាលថ្នាក់ឧត្តមសេនីយ៍។

## ផ្នែកទី៣
## ឯកសណ្ឋាននាយនគរបាល

**មាត្រា១៤ .-**

ឯកសណ្ឋាននាយនគរបាលមានចំនួន៤(បួន)ប្រភេទ រួមមាន ឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ និងឯកសណ្ឋានលេខ៧ ដូចឯកសណ្ឋាននាយនគរបាលជាន់ខ្ពស់ ដែលបានកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ។ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួន ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៩នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោមៈ

ក- មួកកាស្កេត នៅលើគែមក្បាំងមួកមានខ្សែសូតាសភ្លោះពណ៌មាសមួយខ្សែពីជើងមួកម្ខាងទៅជើងមួកម្ខាងទៀត។

ខ- មួកសំបុក នៅលើគែមក្បាំងមួកគ្មានក្បាច់ភ្ញីទេសពណ៌មាស។

គ- មួកហ៊្សកកី នៅលើគែមក្បាំងមួកមានខ្សែសូតាសភ្លោះពណ៌មាសមួយខ្សែពីជើងមួកម្ខាងទៅជើងមួកម្ខាងទៀត។

ឃ- ខ្សែឥស្សរិយយសពណ៌លឿង ធ្វើពីខ្សែនីឡុងសម្រាប់ពាក់លើឯកសណ្ឋានធំលេខ២។

របៀបនៃការប្រើឯកសណ្ឋាននាយនគរបាល ដូចគ្នានឹងការប្រើឯកសណ្ឋាននាយនគរបាលជាន់ខ្ពស់។

នាយនគរបាល នៅពេលចូលរួមក្នុងពិធីផ្លូវការផ្សេងៗ ត្រូវស្លៀកពាក់ឯកសណ្ឋានធំលេខ២ ឬឯកសណ្ឋានលេខ៦និងពាក់ក្រវាត់កពណ៌ខៀវចាស់ ដែលមានឃ្នាបក្រវាត់កពណ៌មាសនៅចំកណ្តាល។

## ផ្នែកទី៤
## ឯកសណ្ឋាននាយនគរបាលរង

**មាត្រា១៥.-**

ឯកសណ្ឋាននាយនគរបាលរងមានចំនួន៣(បី)ប្រភេទ រួមមាន ឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ និងឯកសណ្ឋានលេខ៧ ដូចឯកសណ្ឋាននាយនគរបាល ដែលបានកំណត់ក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ។ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួន ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១០នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- មួកកាស្កេតនិងមួកសំបុកព្រឹន្ទបាល នៅលើជើងមុខមួកមានខ្សែសយសំប៉ែតមួយបន្ទះពណ៌មាស មានទទឹងប្រវែង១៤(ដប់បួន)មិល្លីម៉ែត្រ។ ក្បាំងមួកមានពណ៌ខៀវចាស់លាត។

ខ- មួកកាស្កេតនិងមួកសំបុកពលបាលដូចមួកព្រឹន្ទបាល ប៉ុន្តែនៅលើជើងមុខមួកមានខ្សែសយសំប៉ែតមួយបន្ទះពណ៌ប្រាក់មានទទឹងប្រវែង១៤(ដប់បួន)មិល្លីម៉ែត្រ។ ក្បាំងមួកមានពណ៌ខៀវចាស់លាត។

គ- មួកហ៊្សកកី ព្រឹន្ទបាល និងពលបាល ក្បាំងមួកពណ៌ខៀវចាស់លាត។

របៀបនៃការប្រើឯកសណ្ឋាននាយនគរបាលរង ដូចគ្នានឹងការប្រើឯកសណ្ឋាននាយនគរបាល។

នាយនគរបាលរង នៅពេលចូលរួមក្នុងពិធីផ្លូវការផ្សេងៗ ត្រូវស្លៀកពាក់ឯកសណ្ឋានលេខ៦ និងពាក់ក្រវាត់កពណ៌ខៀវចាស់ ដែលមានឃ្នាបក្រវាត់កពណ៌មាសនៅចំកណ្តាល។

## ជំពូកទី៣
## សញ្ញាសម្គាល់នគរបាលជាតិកម្ពុជា
## ផ្នែកទី១
## រូបព្រះសង្ខារ

**មាត្រា១៦.-**

រូបព្រះសង្ហារមានចំនួន៣(បី)ប្រភេទ យកតាមសញ្ញាជាតិ នៅលើវ័ណ្ឌព្រះសង្ហារមានសរសេរអក្សរ «**ព្រះចៅក្រុងកម្ពុជា**» ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១១នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- រូបព្រះសង្ហារប្រភេទ១ ធ្វើពីលោហធាតុពណ៌មាសសម្រាប់ដាក់នៅលើមុខមួកកាស្កេត។ រូបព្រះសង្ហារប្រភេទនេះមានកម្ពស់៧៨(ចិតសិបប្រាំបី)មិល្លីម៉ែត្រ និងទទឹងប្រវែង៧១(ចិតសិបមួយ)មិល្លីម៉ែត្រ។

២- រូបព្រះសង្ហារប្រភេទ២ ធ្វើពីលោហធាតុពណ៌មាសសម្រាប់ដាក់នៅលើមុខមួកសំបុក និងធ្វើពីក្រណាត់ប៉ាក់សម្រាប់ដាក់នៅលើមុខមួកហ៊្សកកី។ រូបព្រះសង្ហារប្រភេទនេះមានកម្ពស់៥៣(ហាសិបបី)មិល្លីម៉ែត្រ និងទទឹងប្រវែង៥៤(ហាសិបបួន)មិល្លីម៉ែត្រ។

៣- រូបព្រះសង្ហារប្រភេទ៣ ធ្វើពីក្រណាត់ប៉ាក់ពណ៌មាស ផ្ទៃពណ៌ស រឹមព័ទ្ធជុំវិញពណ៌មាស មានរូបកម្រងកួរស្រូវទាំងសងខាង ដែលម្ខាងៗមានគ្រាប់ស្រូវចំនួន១៦(ដប់ប្រាំមួយ)គ្រាប់ ពណ៌មាស អមលម្អទ្រូវរូបព្រះសង្ហាររាងជាស្នែងក្របី សម្រាប់ដាក់នៅលើចំហៀងមួកប៉េរ៉េត៍ ផ្នែកខាងឆ្វេង។ រូបព្រះសង្ហារប្រភេទនេះមានកម្ពស់៤៥(សែសិបប្រាំ)មិល្លីម៉ែត្រ និងទទឹងប្រវែង៥៥(ហាសិបប្រាំ)មិល្លីម៉ែត្រ។

## ផ្នែកទី២
## បន្ទោងរូបរាជសីហ៍

**មាត្រា១៧.-**

បន្ទោងរូបរាជសីហ៍មានចំនួន២(ពីរ)ប្រភេទ សម្រាប់ពាក់បន្ទោកនៅឡេវហោប៉ៅអាវខាងស្តាំផ្ទៃពណ៌ខៀវចាស់រាងមូលមានរឹមពណ៌ប្រាក់ព័ទ្ធជុំវិញ ទំហំ២(ពីរ)មិល្លីម៉ែត្រ មានអង្កត់ផ្ចិត៤៩(សែសិបប្រាំបួន) មិល្លីម៉ែត្រ នៅចំកណ្តាលមានរូបរាជសីហ៍ពណ៌មាសនិងមានកាំពន្លឺពណ៌ប្រាក់ចំនួន១៦(ដប់ប្រាំមួយ)។ នៅខាងក្រោមរូបរាជសីហ៍ មានអក្សរមូលពណ៌ប្រាក់សរសេរកាត់ «**ន ប ជ ក**» នៅក្នុងខ្សែបូពណ៌ខៀវខ្ចី ហើយមានរូបកងចក្រពណ៌ប្រាក់ភ្លឺមានកាំចំនួន២១(ម្ភៃមួយ)ព័ទ្ធជុំវិញ។ បន្ទោងរូបរាជសីហ៍នេះ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១២នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- បន្ទោងរូបរាជសីហ៍ប្រភេទ១ ធ្វើពីលោហធាតុ រាងជាមេដាយ ដែលមានស្បែកបន្ទោកពណ៌ខៀវចាស់ប្រវែង១០០(មួយរយ)មិល្លីម៉ែត្រ បាតស្រួច មានស្លាកសញ្ញារាងមូលពណ៌ប្រាក់ សម្រាប់ពាក់លើឯកសណ្ឋានធំលេខ១ ឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៤ ឯកសណ្ឋានលេខ៥ និងឯកសណ្ឋានលេខ៦។

២- បន្ទោងរូបរាជសីហ៍ប្រភេទ២ ធ្វើពីក្រណាត់ប៉ាក់ រាងជាមេដាយ ដែលមានក្រណាត់បន្ទោកពណ៌ខៀវចាស់ប្រវែង១០០(មួយរយ)មិល្លីម៉ែត្រ បាតស្រួច មានស្លាកសញ្ញារាងមូលពណ៌ប្រាក់ សម្រាប់ពាក់លើឯកសណ្ឋានលេខ៧។

## ផ្នែកទី៣
## ស្លាកសញ្ញាដាក់លើដៃអាវខាងស្តាំ

**មាត្រា១៨.-**

ស្លាកសញ្ញាដាក់លើដៃអាវខាងស្តាំធ្វើពីក្រណាត់ប៉ាក់រាងមូល ចុះពីថ្នេរស្មាចម្ងាយប្រវែង៧៥ (ចិតសិបប្រាំ)មិល្លីម៉ែត្រ ផ្ទៃពណ៌ទង់ជាតិ ដែលមានអង្កត់ផ្ចិត៧៧(ចិតសិបប្រាំពីរ)មិល្លីម៉ែត្រ មានរឹមព័ទ្ធជុំវិញពណ៌សទំហំ២(ពីរ)មិល្លីម៉ែត្រ។ នៅផ្នែកខាងលើមួយភាគបួន មានផ្ទៃពណ៌ខៀវ ដែលមានអក្សរមូលពណ៌ស សរសេរកាត់ថា «**ន ប**» មានកម្ពស់១២ (ដប់ពីរ)មិល្លីម៉ែត្រ។ នៅផ្នែកខាងក្រោមលើផ្ទៃពណ៌ខៀវមានអក្សរឡាតាំងសរសេរថា «POLICE» មានកម្ពស់១០(ដប់)មិល្លីម៉ែត្រ។ នៅចំកណ្តាលលើផ្ទៃពណ៌ក្រហម មានរូបប្រាសាទកំពូលបីពណ៌ស មានកម្ពស់២២(ម្ភៃពីរ)មិល្លីម៉ែត្រ និងបាតប្រវែង៣៤(សាមសិបបួន) មិល្លីម៉ែត្រ សម្រាប់ដាក់លើដៃអាវខាងស្តាំនៃឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៤ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ និងឯកសណ្ឋានលេខ៧ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៣នៃអនុក្រឹត្យនេះ។

## ផ្នែកទី៤
## ស្លាកសញ្ញាដាក់លើដៃអាវខាងឆ្វេង

**មាត្រា១៩.-**

ស្លាកសញ្ញាដាក់លើដៃអាវខាងឆ្វេងធ្វើពីក្រណាត់ប៉ាក់រាងកោង ចុះពីថ្នេរស្មាចម្ងាយប្រវែង៥០ (ហាសិប)មិល្លីម៉ែត្រ ផ្ទៃពណ៌ទង់ជាតិ ដែលមានបណ្តោយខាងលើប្រវែង១០៥(មួយរយប្រាំ)មិល្លីម៉ែត្រ បណ្តោយខាងក្រោមប្រវែង៧០(ចិតសិប)មិល្លីម៉ែត្រ និងទទឹងប្រវែង២០(ម្ភៃ)មិល្លីម៉ែត្រ មានរឹមព័ទ្ធជុំវិញពណ៌សទំហំ២(ពីរ)មិល្លីម៉ែត្រ។ នៅចំកណ្តាលលើផ្ទៃពណ៌ក្រហមមានអក្សរមូលពណ៌ស សរសេរថា «**នគរបាលជាតិកម្ពុជា**» អក្សរមានកម្ពស់៨(ប្រាំបី)មិល្លីម៉ែត្រ សម្រាប់ដាក់លើដៃអាវខាងឆ្វេងនៃឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៤ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ និងឯកសណ្ឋានលេខ៧ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៤នៃអនុក្រឹត្យនេះ។



៤

## ផ្នែកទី៥
## សញ្ញាពាក់លើចុងកអាវ

**មាត្រា២០.-**

សញ្ញាពាក់លើចុងកអាវនៃឯកសណ្ឋានធំលេខ១ ឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៤ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ និងឯកសណ្ឋានលេខ៧ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៥ នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- សញ្ញាពាក់លើចុងកអាវទាំងសងខាងនៃឯកសណ្ឋានធំលេខ១ ធ្វើពីក្រណាត់ប៉ាក់រាងចតុកោណ ផ្ទៃពណ៌មាសដែលមានបណ្តោយប្រវែង៧០(ចិតសិប)មិល្លីម៉ែត្រ ទទឹងដើមប្រវែង៣០(សាមសិប)មិល្លីម៉ែត្រ និងទទឹងចុងប្រវែង៤០(សែសិប)មិល្លីម៉ែត្រ មានក្បាច់កម្រងកួរស្រូវទាំងសងខាង ដែលម្ខាងៗមានគ្រាប់ស្រូវចំនួន៣៦(សាមសិបប្រាំមួយ)គ្រាប់ពណ៌មាស។

២- សញ្ញាពាក់លើចុងកអាវទាំងសងខាងនៃឯកសណ្ឋានធំលេខ២និងឯកសណ្ឋានលេខ៤ ត្រូវពាក់បញ្ឈរ ឯកសណ្ឋានលេខ៥និងឯកសណ្ឋានលេខ៦ ត្រូវពាក់បញ្ឆិត ធ្វើពីលោហធាតុពណ៌មាសមានរាងមូល ដែលមានអង្កត់ផ្ចិត២៥(ម្ភៃប្រាំ)មិល្លីម៉ែត្រ មានរូបជើងពានទ្រតម្កល់រដ្ឋធម្មនុញ្ញ។ នៅខាងលើមានរូបព្រះខ័នពីរខ្វែងគ្នា មានកម្រងកួរស្រូវទាំងសងខាង ដែលម្ខាងៗមានគ្រាប់ស្រូវចំនួន១៦(ដប់ប្រាំមួយ)គ្រាប់ អមលម្អទ្រជារាងស្នែងក្របី និងមានទងបំបែកចេញពីរូបផ្កាដកចន្ទន៍។

នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ត្រូវប្រើសញ្ញាពាក់លើចុងកអាវពណ៌មាស។ រីឯនាយនគរបាលនិងនាយនគរបាលរង ត្រូវប្រើសញ្ញាពាក់លើចុងកអាវពណ៌ប្រាក់ភ្លឺ។

៣- សញ្ញាពាក់លើចុងកអាវខាងស្តាំនៃឯកសណ្ឋានលេខ៧ ធ្វើពីក្រណាត់ផ្ទៃពណ៌ខៀវចាស់រាងទ្រវែង ខាងដើមរាងមូលនិងខាងចុងស្រួច ដែលមានបណ្តោយប្រវែង៥២(ហាសិបពីរ)មិល្លីម៉ែត្រ និងទទឹងប្រវែង៣២(សាមសិបពីរ)មិល្លីម៉ែត្រ មានរឹមព័ទ្ធជុំវិញ នៅកណ្តាលធ្វើពីក្រណាត់ប៉ាក់មានរាងមូល ដែលមានអង្កត់ផ្ចិត២២(ម្ភៃពីរ)មិល្លីម៉ែត្រ មានរូបជើងពានទ្រតម្កល់រដ្ឋធម្មនុញ្ញ។ នៅខាងលើមានរូបព្រះខ័នពីរខ្វែងគ្នា ហើយមានកម្រងកួរស្រូវទាំងសងខាងដែលម្ខាងៗមានគ្រាប់ស្រូវចំនួន១៦(ដប់ប្រាំមួយ)គ្រាប់ អមលម្អទ្រជារាងស្នែងក្របី និងមានទងបំបែកចេញពីរូបផ្កាដកចន្ទន៍ សម្រាប់ប្រើដូចខាងក្រោម៖

ក- នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ត្រូវប្រើសញ្ញាពាក់លើចុងកអាវខាងស្តាំពណ៌មាសមានរឹម និងក្បាច់ភ្ញីទេសព័ទ្ធជុំវិញពណ៌មាសទំហំ៥(ប្រាំ)មិល្លីម៉ែត្រ។

ខ- នាយនគរបាលជាន់ខ្ពស់ ត្រូវប្រើសញ្ញាពាក់លើចុងកអាវខាងស្តាំពណ៌មាសមានរឹមព័ទ្ធជុំវិញពណ៌ខ្មៅទំហំ២(ពីរ)មិល្លីម៉ែត្រ។

គ- នាយនគរបាលនិងនាយនគរបាលរង ត្រូវប្រើសញ្ញាពាក់លើចុងកអាវខាងស្តាំពណ៌ប្រាក់ភ្លឺ មានរឹមព័ទ្ធជុំវិញពណ៌ខ្មៅទំហំ២(ពីរ)មិល្លីម៉ែត្រ។

## ផ្នែកទី៦
## សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ

**មាត្រា២១.-**

សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ មានចំនួន២(ពីរ)ប្រភេទ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៦នៃអនុក្រឹត្យនេះ រួមមាន៖

១- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ១ ធ្វើពីលោហធាតុពណ៌មាស ដែលមានរូបនាគក្បាលប្រាំដកពពារ ដោយរូបផ្កាយទ្រដោយកម្រងកួរស្រូវទាំងសងខាង ដែលម្ខាងៗមានគ្រាប់ស្រូវចំនួន១៦(ដប់ប្រាំមួយ)គ្រាប់ អមលម្អទ្រជារាងស្នែងក្របី ហើយមានក្បាច់កន្ទុយហង្សអមទាំងសងខាង មានបណ្តោយប្រវែង៦០(ហុកសិប)មិល្លីម៉ែត្រ និងទទឹងប្រវែង៣០(សាមសិប)មិល្លីម៉ែត្រ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលចាប់ពី១៦ឆ្នាំឡើង មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមានចំនួន៥(ប្រាំ)សន្លឹក។

ខ- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលចាប់ពី៨ឆ្នាំ ដល់ក្រោម១៦ឆ្នាំ មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមានចំនួន៣(បី)សន្លឹក។

គ- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលក្រោម៨ឆ្នាំ មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមាន១(មួយ)សន្លឹក។

២- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ២ ដូចសញ្ញាសម្គាល់អតីតភាពប្រភេទ១ ធ្វើពីក្រណាត់ប៉ាក់ពណ៌មាសលើក្រណាត់ពណ៌ខៀវចាស់រាងចតុកោណកែងបណ្តោយប្រវែង៦៥(ហុកសិបប្រាំ)មិល្លីម៉ែត្រ និង ទទឹងប្រវែង៣៥(សាមសិបប្រាំ)មិល្លីម៉ែត្រ ដែលមានរឹមបន្ទាត់ពណ៌ខ្មៅព័ទ្ធជុំវិញទំហំ២(ពីរ)មិល្លីម៉ែត្រ។

សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ១ ត្រូវពាក់លើហោប៉ៅអាវខាងស្តាំផ្នែកខាងលើផ្លាកឈ្មោះ និងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជានៃឯកសណ្ឋានធំលេខ១ ឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៤ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ ឬត្រូវពាក់លើអាវផ្នែកខាងស្តាំខាងលើផ្លាកឈ្មោះនិងអត្តលេខនៃឯកសណ្ឋានធំលេខ៣ និងសញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ២ ត្រូវពាក់លើហោប៉ៅអាវខាងស្តាំផ្នែកខាងលើស្លាកឈ្មោះនិងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជានៃឯកសណ្ឋានលេខ៧។

**មាត្រា២២._**

សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិនាយនគរបាលជាន់ខ្ពស់ មានចំនួន២(ពីរ)ប្រភេទ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៧នៃអនុក្រឹត្យនេះ រួមមាន៖

១- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ១ ធ្វើពីលោហធាតុពណ៌មាស ដែលមានរូបរាជសីហ៍ទ្រដោយកម្រងកួរស្រូវទាំងសងខាង ដែលម្ខាងៗមានគ្រាប់ស្រូវចំនួន១៦(ដប់ប្រាំមួយ)គ្រាប់អមលម្អទ្រជារាងស្នែងក្របី មានក្បាច់កន្ទុយហង្សអមទាំងសងខាង មានបណ្តោយប្រវែង៦០(ហុកសិប)មិល្លីម៉ែត្រ និងទទឹងប្រវែង៣០(សាមសិប)មិល្លីម៉ែត្រ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលចាប់ពី១២ឆ្នាំឡើង មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមានចំនួន៥(ប្រាំ)សន្លឹក។

ខ- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលចាប់ពី៦ឆ្នាំ ដល់ក្រោម១២ឆ្នាំ មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមានចំនួន៣(បី)សន្លឹក។

គ- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលក្រោម៦ឆ្នាំ មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមាន១(មួយ)សន្លឹក។

២- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ២ ដូចសញ្ញាសម្គាល់អតីតភាពប្រភេទ១ ធ្វើពីក្រណាត់ប៉ាក់ពណ៌មាសលើក្រណាត់ពណ៌ខៀវចាស់រាងចតុកោណកែងបណ្តោយប្រវែង៦៥(ហុកសិបប្រាំ)មិល្លីម៉ែត្រ និងទទឹងប្រវែង៣៥(សាមសិបប្រាំ)មិល្លីម៉ែត្រ ដែលមានរឹមបន្ទាត់ពណ៌ខ្មៅព័ទ្ធជុំវិញទំហំ២(ពីរ)មិល្លីម៉ែត្រ។



៥

សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ១ ត្រូវពាក់លើហោប៉ៅអាវខាងស្តាំផ្នែកខាងលើផ្លាកឈ្មោះ និងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជានៃឯកសណ្ឋានធំលេខ១ ឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៤ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ ឬត្រូវពាក់លើអាវផ្នែកខាងស្តាំខាងលើផ្លាកឈ្មោះនិងអត្តលេខ នៃឯកសណ្ឋានធំលេខ៣ និងសញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ២ ត្រូវពាក់លើហោប៉ៅអាវខាងស្តាំផ្នែកខាងលើស្លាកឈ្មោះនិងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជានៃឯកសណ្ឋានលេខ៧។

**មាត្រា២៣.-**

សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិនាយនគរបាល មានចំនួន២(ពីរ)ប្រភេទ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៨នៃអនុក្រឹត្យនេះ រួមមាន៖

១- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ១ ធ្វើពីលោហធាតុ ដែលមានរូបរាជសីហ៍ពណ៌ប្រាក់ទ្រដោយកម្រងកួរស្រូវទាំងសងខាង ដែលម្ខាងៗមានគ្រាប់ស្រូវចំនួន១៦(ដប់ប្រាំមួយ)គ្រាប់ អមលម្អទ្រដារាងស្នែងក្របីពណ៌ប្រាក់ ហើយមានរូបក្បាច់កន្ទុយហង្សអមទាំងសងខាងពណ៌មាស មានបណ្តោយប្រវែង៦០(ហុកសិប)មិល្លីម៉ែត្រ និងទទឹងប្រវែង៣០(សាមសិប)មិល្លីម៉ែត្រ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលចាប់ពី៨ឆ្នាំឡើង មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមានចំនួន៥(ប្រាំ)សន្លឹក។

ខ- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលចាប់ពី៤ឆ្នាំ ដល់ក្រោម៨ឆ្នាំ មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមានចំនួន៣(បី)សន្លឹក។

គ- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលក្រោម៤ឆ្នាំ មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមាន១(មួយ)សន្លឹក។

២- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ២ ដូចសញ្ញាសម្គាល់អតីតភាពប្រភេទ១ ធ្វើពីក្រណាត់ប៉ាក់រូបរាជសីហ៍ទ្រដោយកម្រងកួរស្រូវពណ៌ប្រាក់ និងប៉ាក់ក្បាច់កន្ទុយហង្សពណ៌មាស លើក្រណាត់ពណ៌ខៀវចាស់រាងចតុកោណកែងបណ្តោយប្រវែង៦៥(ហុកសិបប្រាំ)មិល្លីម៉ែត្រ និងទទឹងប្រវែង៣៥(សាមសិបប្រាំ) មិល្លីម៉ែត្រ ដែលមានរឹមបន្ទាត់ពណ៌ខ្មៅព័ទ្ធជុំវិញទំហំ២(ពីរ)មិល្លីម៉ែត្រ។

សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ១ ត្រូវពាក់លើហោប៉ៅអាវខាងស្តាំផ្នែកខាងលើផ្លាកឈ្មោះ និងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជានៃឯកសណ្ឋានធំលេខ២ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ និងសញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ២ ត្រូវពាក់លើហោប៉ៅអាវខាងស្តាំផ្នែកខាងលើស្លាកឈ្មោះនិងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជានៃឯកសណ្ឋានលេខ៧។

**មាត្រា២៤.-**

សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិនាយនគរបាលរង មានចំនួន២(ពីរ)ប្រភេទ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៩នៃអនុក្រឹត្យនេះ រួមមាន៖

១- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ១ ធ្វើពីលោហធាតុពណ៌ប្រាក់ ដែលមានរូបរាជសីហ៍ទ្រដោយកម្រងកួរស្រូវទាំងសងខាង ដែលម្ខាងៗមានគ្រាប់ស្រូវចំនួន១៦(ដប់ប្រាំមួយ)គ្រាប់ អមលម្អទ្រដារាងស្នែងក្របី ហើយមានរូបក្បាច់កន្ទុយហង្សអមទាំងសងខាង មានបណ្តោយប្រវែង៦០(ហុកសិប)មិល្លីម៉ែត្រ និងទទឹងប្រវែង៣០(សាមសិប)មិល្លីម៉ែត្រ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលចាប់ពី៦ឆ្នាំឡើង មានរូបក្បាច់កន្ទុយហង្ស នៅទាំងសងខាង ដែលម្ខាងៗមានចំនួន៥(ប្រាំ)សន្លឹក។

ខ- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលចាប់ពី៣ឆ្នាំ ដល់ក្រោម៦ឆ្នាំ មានរូបក្បាច់កន្ទុយហង្សនៅទាំងសងខាង ដែលម្ខាងៗមានចំនួន៣(បី)សន្លឹក។

គ- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិ រយៈពេលក្រោម៣ឆ្នាំ មានរូបក្បាច់កន្ទុយហង្ស នៅទាំងសងខាង ដែលម្ខាងៗមាន១(មួយ)សន្លឹក។

២- សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ២ ដូចសញ្ញាសម្គាល់អតីតភាពប្រភេទ១ ធ្វើពីក្រណាត់ប៉ាក់ពណ៌ប្រាក់ លើក្រណាត់ពណ៌ខៀវចាស់រាងចតុកោណកែងបណ្តោយប្រវែង៦៥(ហុកសិបប្រាំ)មិល្លីម៉ែត្រ និងទទឹងប្រវែង៣៥(សាមសិបប្រាំ)មិល្លីម៉ែត្រ ដែលមានរឹមបន្ទាត់ពណ៌ខ្មៅព័ទ្ធជុំវិញទំហំ២(ពីរ)មិល្លីម៉ែត្រ។

សញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ១ ត្រូវពាក់លើហោប៉ៅអាវខាងស្តាំផ្នែកខាងលើផ្លាកឈ្មោះ និងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជានៃឯកសណ្ឋានលេខ៥ ឯកសណ្ឋានលេខ៦ និងសញ្ញាសម្គាល់អតីតភាពឋានន្តរសក្តិប្រភេទ២ ត្រូវពាក់លើហោប៉ៅអាវខាងស្តាំផ្នែកខាងលើស្លាកឈ្មោះនិងអត្តលេខសម្គាល់មន្ត្រីនគរបាលជាតិកម្ពុជានៃឯកសណ្ឋានលេខ៧។

## ផ្នែកទី៧
## សញ្ញាសម្គាល់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

### មាត្រា២៥.-

សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ពាក់នៅលើហោប៉ៅអាវខាងឆ្វេងនៃឯកសណ្ឋានធំលេខ១ ឯកសណ្ឋានធំលេខ២ ឯកសណ្ឋានធំលេខ៣ ឯកសណ្ឋានលេខ៤ ឯកសណ្ឋានលេខ៥ និងឯកសណ្ឋានលេខ៦ ឬពាក់តួមេដាយគ្រឿងឥស្សរិយយស នៅលើឯកសណ្ឋានធំលេខ១ និងឯកសណ្ឋានធំលេខ២ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៨
## សញ្ញាសក្តិ

### មាត្រា២៦.-

